# ព្រះរាជក្រឹត្យ

នស/រកត/០៥០៩/៥៧៣

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០៩/ ៥៧៣ ចុះថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០០៩ ស្តីពីការកំណត់ការទទួលស្គាល់សមាសភាពសមាជិកក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានទ្រង់យល់សេចក្តីសម្រេចរបស់ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត លេខ ១៣៧ គ.ជ.ប.សសរ ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០០៩ ស្តីពីបេក្ខជនជាប់ឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានទទួលស្គាល់សមាសភាពក្រុមប្រឹក្សារាជធានីភ្នំពេញ ក្នុងអាណត្តិទី១ ដូចមានរាយនាមខាងក្រោម :

| | |
|---|---|
| ១- ឯកឧត្តម ម៉ុម សារិន | ជាប្រធានក្រុមប្រឹក្សារាជធានី |
| ២- ឯកឧត្តម ឡោក ធឿរ | ជាសមាជិកក្រុមប្រឹក្សារាជធានី |
| ៣- ឯកឧត្តម ជួប ខុន | ជាសមាជិកក្រុមប្រឹក្សារាជធានី |

ROYAUME DU CAMBODGE * LE MINISTÈRE DU PALAIS ROYAL * ក្រសួងព្រះបរមរាជវាំង

| | |
|---|---|
| ៤- ឯកឧត្តម ជា សុធន | ជាសមាជិកក្រុមប្រឹក្សារាជធានី |
| ៥- ឯកឧត្តម អ៊ុំ ហ៊ឿន | ជាសមាជិកក្រុមប្រឹក្សារាជធានី |
| ៦- ឯកឧត្តម ទេីង ថៃ | ជាសមាជិកក្រុមប្រឹក្សារាជធានី |
| ៧- ឯកឧត្តម នុត ជា | ជាសមាជិកក្រុមប្រឹក្សារាជធានី |
| ៨- ឯកឧត្តម លឹស រី | ជាសមាជិកក្រុមប្រឹក្សារាជធានី |
| ៩- ឯកឧត្តម ព្រហ្ម គន្ធ | ជាសមាជិកក្រុមប្រឹក្សារាជធានី |
| ១០- ឯកឧត្តម ហែម ឡុងសុគន្ធ្រ | ជាសមាជិកក្រុមប្រឹក្សារាជធានី |
| ១១- លោកជំទាវ មុំ គ្រួសាល | ជាសមាជិកក្រុមប្រឹក្សារាជធានី |
| ១២- ឯកឧត្តម ឈាត នារាណាឌុង | ជាសមាជិកក្រុមប្រឹក្សារាជធានី |
| ១៣- លោកជំទាវ ឃួន គីមនី | ជាសមាជិកក្រុមប្រឹក្សារាជធានី |
| ១៤- ឯកឧត្តម ចណ្ណ សុខខេង | ជាសមាជិកក្រុមប្រឹក្សារាជធានី |
| ១៥- ឯកឧត្តម ថាច់ សេដ្ឋា | ជាសមាជិកក្រុមប្រឹក្សារាជធានី |
| ១៦- ឯកឧត្តម ម៉ន ផល្លា | ជាសមាជិកក្រុមប្រឹក្សារាជធានី |
| ១៧- ឯកឧត្តម ចេប គីមអាង | ជាសមាជិកក្រុមប្រឹក្សារាជធានី |
| ១៨- លោកជំទាវ ហ៊ុង សុគុំម | ជាសមាជិកក្រុមប្រឹក្សារាជធានី |
| ១៩- ឯកឧត្តម សៀល ខេមរិន្ទ្រ | ជាសមាជិកក្រុមប្រឹក្សារាជធានី |
| ២០- ឯកឧត្តម សុក សេក | ជាសមាជិកក្រុមប្រឹក្សារាជធានី |
| ២១- ឯកឧត្តម គាត់ ភុម្ភារ | ជាសមាជិកក្រុមប្រឹក្សារាជធានី ។ |

**មាត្រា ២ :** ក្នុងករណីមានសមាជិកក្រុមប្រឹក្សាណាម្នាក់បាត់បង់សមាជិកភាព ពីក្រុមប្រឹក្សា ត្រូវអនុវត្តតាមបទបញ្ញត្តិ នៃ មាត្រា ២២ និង មាត្រា ២៣ នៃច្បាប់ ស្តីពី ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

**មាត្រា ៣ :** ក្នុងការអនុវត្តការងារ ប្រធាន និងសមាជិកក្រុមប្រឹក្សារាជធានីភ្នំពេញ ត្រូវអនុវត្តតាមរដ្ឋធម្មនុញ្ញ ច្បាប់ និងលិខិតបទដ្ឋាននានាជាធរមាន ។

**មាត្រា ៤ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៥ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៦ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

តរល.០៩០៥.៥៤៥

នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០០៩

លេខ ៥៣៥ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ២០០៩

អគ្គលេខាធិការរាជរដ្ឋាភិបាល

ឃុន ចិនកេន